**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

លេខ:០១ សសរ ក.ស.វ.

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតអនុក្រុមការងារសិក្សាស្រាវជ្រាវអំពីជីវភាពរស់នៅរបស់ប្រជាជន

## ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
## ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៧៣ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៨/១៣៩៣ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការតែងតាំង និងផ្តល់ឋានៈដល់សមាសភាពថ្នាក់ដឹកនាំ និងសមាជិកអចិន្ត្រៃយ៍ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៩/២៤២ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការតែងតាំង និងផ្តល់ឋានៈដល់ទីប្រឹក្សាបច្ចេកទេសក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

-បានឃើញអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

-បានឃើញសេចក្តីសម្រេចលេខ៤០ សសរ ក.ស.វ. ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២០ ស្តីពីបង្កើតក្រុមការងារសិក្សាស្រាវជ្រាវរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

-យោងតាមតម្រូវការចាំបាច់



Office of the Council of Ministers
Economic, Social and Cultural Council (ECOSOCC)
Address: #41, Russian Federation Blvd.
ទូរស័ព្ទ/ទូរសារ : (៨៥៥)-២៣ ២១ ១៩ ៤៣ , Tel/Fax : (855)-23 21 19 43

# សម្រេច

**ប្រការ១.**

ត្រូវបានបង្កើតអនុក្រុមការងារសិក្សាស្រាវជ្រាវអំពីជីវភាពរស់របស់ប្រជាជន ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | ឯកឧត្តម **ទូច ស៊ាងតាណា** | ប្រធាន |
| ២. | ឯកឧត្តម **ញឹម បូរ៉ាន** | អនុប្រធាន |
| ៣. | ឯកឧត្តម **ប៉ិច សុខា** | អនុប្រធាន |
| ៤. | ឯកឧត្តម **ប៉ែន សារឿន** | សមាជិក |
| ៥. | ឯកឧត្តម **ឌិន វីរៈ** | សមាជិក |
| ៦. | ឯកឧត្តម **នៅ បោននរ័** | សមាជិក |
| ៧. | ឯកឧត្តម **លឿង ស៊ីម៉ូណា** | សមាជិក |
| ៨. | ឯកឧត្តម **ម៉ម សារិទ្ធ** | សមាជិក |
| ៩. | ឯកឧត្តម **ពេជ្រ ភិរម្យ** | សមាជិក |
| ១០. | ឯកឧត្តម **កយ បូរី** | សមាជិក |
| ១១. | ឯកឧត្តម **អេង រត្នមុនី** | សមាជិក |
| ១២. | លោកជំទាវ **ស៊ាង សុផល្លា** | សមាជិក |
| ១៣. | ឯកឧត្តម **ឡោ ប៉ូលីណា** | សមាជិក |
| ១៤. | ឯកឧត្តម **សំ សំណាង** | ជំនួយការ |
| ១៥. | លោក **លី ជាណា** | ជំនួយការ |
| ១៦. | លោក **ពិន សុធា** | ជំនួយការ |
| ១៧. | លោក **ហេង សុភៈបញ្ញា** | ជំនួយការ |
| ១៨. | លោក **អៀង រដ្ឋា** | ជំនួយការ |
| ១៩. | លោក **នូ ពេជ្រខុងម៉េង** | លេខាធិការ |
| ២០. | លោក **ឃឹម ច័ន្ទតារា** | លេខាធិការ |
| ២១. | លោក **អ៊ុំ វិចិត្រ** | លេខាធិការ |
| ២២. | លោក **នីវ កុសល** | លេខាធិការ |
| ២៣. | លោក **ជី ដានីត** | លេខាធិការ |
| ២៤. | កញ្ញា **អ៊ឹង សុគន្ធាវី** | លេខាធិការ។ |

ប្រធានអនុក្រុមការងារ អាចស្នើសុំទីប្រឹក្សាបច្ចេកទេស សមាជិកក.ស.វ. និង/ឬ មន្ត្រីអគ្គលេខាធិការដ្ឋានបន្ថែមទៀត ដើម្បីជួយការងារគម្រោងតាមការចាំបាច់។

**ប្រការ២..**

អនុក្រុមការងារសិក្សាស្រាវជ្រាវអំពីជីវភាពរស់នៅរបស់ប្រជាជន មានភារកិច្ចដូចតទៅ៖

- ដឹកនាំការងារបច្ចេកទេសដើម្បីអនុវត្តគម្រោងសិក្សាស្រាវជ្រាវ
- រៀបចំវិធីសាស្ត្រនិងនីតិវិធីសម្រាប់សិក្សាស្រាវជ្រាវ
- រៀបចំកម្រងសំនួរសម្រាប់សិក្សាស្រាវជ្រាវ
- រៀបចំផែនការមេ និងផែនការសកម្មភាព ដែលត្រូវចុះអនុវត្តជាក់ស្តែង
- រៀបចំសេចក្តីព្រាងគម្រោងថវិកា និងផែនការភស្តុភារសម្រាប់បម្រើការងារគម្រោង
- បណ្តុះបណ្តាល និងបំពាក់បំប៉ន មន្ត្រីបង្គោល និងអ្នកចុះសម្ភាសន៍
- រៀបចំបែងចែកការងារឲ្យមន្ត្រីបង្គោល ដើម្បីដឹកនាំការចុះសម្ភាសន៍តាមបណ្តាខេត្តនីមួយៗ
- សិក្សាស្រាវជ្រាវឯកសារពាក់ព័ន្ធដែលអាចរកបាននៅតាមបណ្ណសារនិងគេហទំព័រ
- ទំនាក់ទំនងនិងចុះជួបដើម្បីពិភាក្សាការងារជាមួយក្រសួងស្ថាប័ន ថ្នាក់ជាតិ-ក្រោមជាតិពាក់ព័ន្ធ
- រៀបចំលិខិតបេសកកម្ម មធ្យោបាយធ្វើដំណើរ ការស្នាក់នៅ ហូបចុក ក្នុងកំឡុងពេលបំពេញបេសកកម្មរបស់អ្នកចុះសម្ភាសន៍
- ដឹកនាំនិងចុះសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ ដែលរួមមានមន្ត្រីរដ្ឋបាលឬជាប់ទាក់ទងនឹងការងារជំនាញនៅគ្រប់ថ្នាក់ និងអ្នកទទួលខុសត្រូវគ្រឹះស្ថានឯកជនដែលជាប់ពាក់ព័ន្ធ
- ជ្រើសរើសអ្នកជំនាញផ្នែកប្រព័ន្ធគ្រប់គ្រងកម្មវិធីកុំព្យូទ័រសម្រាប់វិភាគទិន្នន័យ និងអ្នកបញ្ចូលទិន្នន័យ
- ជ្រើសរើសអ្នកចុះសម្ភាសន៍ផ្ទាល់តាមតម្រូវការចាំបាច់
- ជាមន្ត្រីបង្គោល ទទួលបន្ទុកបណ្តុះបណ្តាលបន្តដល់អ្នកចុះសម្ភាសន៍ផ្ទាល់ និងដឹកនាំការសម្ភាសន៍ទៅតាមគោលដៅកំណត់
- ចុះធ្វើសម្ភាសន៍ជាក់ស្តែងនៅមូលដ្ឋាន និងផ្ទៀងផ្ទាត់លទ្ធផលការងារប្រចាំថ្ងៃ
- តាមដាន ត្រួតពិនិត្យលើវឌ្ឍនភាពការងារសិក្សាស្រាវជ្រាវ
- រៀបចំអត្ថបទឯកសារគម្រោងការនិងរបាយការណ៍វិភាគលទ្ធផលនៃការសិក្សាស្រាវជ្រាវ
- រៀបចំរបាយការណ៍ជូនគណៈប្រតិបត្តិក.ស.វ. ដើម្បីពិនិត្យនិងសម្រេច
- រៀបចំបោះពុម្ពនិងធ្វើសិក្ខាសាលាផ្សព្វផ្សាយអំពីលទ្ធផលស្រាវជ្រាវ
- អនុវត្តការងារផ្សេងៗទៀត តាមការណែនាំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រីប្រធានក.ស.វ.។

**ប្រការ៣.-**

អនុប្រធាន សមាជិក ជំនួយការ និងលេខាធិការនៃអនុក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៤.-**

អនុប្រធានប្រចាំការ អនុប្រធាន សមាជិកនៃក.ស.វ. អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានផ្នែក អនុប្រធានផ្នែក មន្ត្រីនៃអគ្គលេខាធិការដ្ឋានក.ស.វ. និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ច័ន្ទ ១៤កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០

**ទេសរដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**យឹម ណុលឡា**

***កន្លែងទទួល៖***

*- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*

*- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រីប្រធានក.ស.វ.*

*- ដូចប្រការ៤*

*- ឯកសារ កាលប្បវត្តិ*